អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

*រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ កក្កដា ឆ្នាំ២០២១*

# សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") ត្រូវបង្ខំចិត្តចេញសេចក្តីប្រកាសព័ត៌មាននេះ ដើម្បីឆ្លើយតបទៅនឹងការចោទប្រកាន់មិនត្រឹមត្រូវគ្មានមូលដ្ឋាន ទាក់ទងនឹងការប្រព្រឹត្តមិនត្រឹមត្រូវក្នុងសេចក្តីប្រកាសព័ត៌មានចេញដោយមេធាវីការពារក្តី មាស មុត នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ ដែលបង្ហាញពីការខកចិត្តរបស់ពួកគេចំពោះការអនុវត្តឆន្ទានុសិទ្ធិដ៏ត្រឹមត្រូវរបស់អង្គបុរេជំនុំជម្រះ ក្នុងការបដិសេធសំណើរបស់មេធាវីការពារក្តីស្នើសុំដាក់សារណាបន្ថែមមកអង្គបុរេជំនុំជម្រះ។

មិនមានអ្វីគួរឲ្យសង្ស័យទេថា អង្គបុរេជំនុំជម្រះនឹងសម្រេចលើអង្គសេចក្តីនៃអំណះអំណាងដែលមាននៅក្នុងសំណើសុំបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសាររបស់ មាស មុត និងចម្លើយតបរបស់ ស.ព.អ ទៅនឹងសំណើនោះ ដោយមិនចាំបាច់មានជំនួយបន្ថែមពីភាគីណាមួយឡើយ។ ការប្រើប្រាស់សេចក្តីប្រកាសព័ត៌មានរបស់ភាគីមួយ ដើម្បីបង្ហាញដោយប្រយោលអំពីខ្លឹមសារនៃសារណារបស់ខ្លួនដែលត្រូវបានបដិសេធ គឺជាការប្រមាថលើសេចក្តីថ្លៃថ្នូរនៃកិច្ចដំណើរការនីតិវិធីតុលាការ និងមិនគួរទទួលបានការពិចារណាពីអង្គបុរេជំនុំជម្រះឡើយ។

ដើម្បីឲ្យបានច្បាស់ រាល់សារណាទាំងអស់ដែលមានហត្ថលេខារបស់ ស.ព.អ រួមទាំងសារណាដែលរងការវាយប្រហារដោយមេធាវីការពារក្តីនៅពេលនេះផង គឺតំណាងឲ្យការយល់ឃើញរបស់ ស.ព.អ ដោយផ្អែកលើការវាយតម្លៃដោយសុទ្ធចិត្តលើច្បាប់ និងអង្គហេតុដែលពាក់ព័ន្ធទៅនឹងអំណះអំណាង ដែលមេធាវីការពារក្តីជ្រើសរើសធ្វើឡើង និងភាសាដែលមេធាវីការពារក្តីជ្រើសរើសប្រើ។ ហេតុដូច្នេះ អ្នកធ្វើការចោទប្រកាន់ណាមួយអំពីការប្រព្រឹត្តមិនត្រឹមត្រូវ ត្រូវតែមានសុចរិតភាព និងសេចក្តីក្លាហាន ក្នុងការតម្រង់ការចោទប្រកាន់ទាំងនោះមកកាន់ ស.ព.អ និងមិនមែននិយាយបង្កាច់បុគ្គលិកប្រកបដោយវិជ្ជាជីវៈរបស់ ស.ព.អ ដែលតែងតែប្រកាន់ខ្ជាប់នូវបទដ្ឋានសីលធម៌ខ្ពស់បំផុត ដូចគ្នានឹង ស.ព.អ ដែរនោះទេ។

ហេតុដូច្នេះ ស.ព.អ បដិសេធយ៉ាងដាច់អហង្ការចំពោះការចោទប្រកាន់គ្មានមូលដ្ឋាន ឥតអៀនខ្មាសអំពីការប្រព្រឹត្តមិនត្រឹមត្រូវ ដែលមាននៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់មេធាវីការពារក្តី និងសូមទុកឱ្យអង្គបុរេជំនុំជម្រះធ្វើការសម្រេចលើបញ្ហានេះនៅចំពោះមុខខ្លួន ដោយផ្អែកលើច្បាប់និងអង្គហេតុពាក់ព័ន្ធ និងសារណាដែលបានទទួលយកយ៉ាងត្រឹមត្រូវ៕